ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការផ្តល់ព័ត៌មានសុរិយោដី
# តាមប្រព័ន្ធអេឡិចត្រូនិក

ឆ្នាំ ២០១៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤១៤ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្ដីពី
## ការផ្ដល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .–**

នៅក្នុងប្រកាសអន្តរក្រសួងនេះ ពាក្យ “**ព័ត៌មានសុរិយោដី**” សំដៅដល់ព័ត៌មានអំពីការជាប់បន្ទុក ឬ គ្មានជាប់បន្ទុកនៃអចលនវត្ថុណាមួយ ដែលរួមមានព័ត៌មានទាក់ទងនឹងឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សេវភាព ការរឹបអូស ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ការហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ។

**ប្រការ៣ .–**

ការប្រមូលចំណូលពីកម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវធ្វើឡើងតាមរយៈគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់តម្លៃ ២០.០០០(ម្ភៃពាន់) រៀល ក្នុងមួយប្រតិបត្តិការ ដោយគិតបញ្ចូលរួមទាំងកម្រៃសេវារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ។

ចំណូលប្រមូលបានពីកម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ជាកម្មវត្ថុសម្រាប់ការទូទាត់កម្រៃសេវារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ។ ចំណូលដែលនៅសល់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ៤ .–**

លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៥ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រកាសអន្តរក្រសួងនេះ ព្រមទាំងលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

អតិថិជនដែលមានបំណងប្រើប្រាស់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក អាចសាកសួរព័ត៌មាន និងរបៀបនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬ នៅការិយាល័យច្រកចេញចូលតែមួយនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៦ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់។

នៅពេលអនុវត្តចំណូល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៧ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៨ .-**

កម្រៃសេវាផ្តល់ព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានកំណត់នៅក្នុងប្រការ៣ នៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០២០ តទៅ។

ថ្ងៃ[illegible] ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

# របៀបពិនិត្យព័ត៌មានសុរិយោដី តាមប្រព័ន្ធអេឡិចត្រូនិក






## ១ ស្កេន QR Code លើសន្លឹកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ

នៅពេលលោកអ្នកស្កេន QR Code លើសន្លឹកវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ លោកអ្នកនឹងទទួលព័ត៌មាន អំពីក្បាលដីមានជាអាទិ៍÷

- ទីតាំងក្បាលដី
- លេខក្បាលដី
- ទំហំដី
- ប្រភេទទ្រព្យ
- ម្ចាស់កម្មសិទ្ធិ ដូចមានក្នុងរូបខាងស្តាំ

ព័ត៌មាននេះ ផ្តល់ជូនលោកអ្នកដោយឥតគិតថ្លៃ




## ២ ការចូលមើលព័ត៌មានអំពីបន្ទុកលើអចលនវត្ថុ

ដើម្បីចូលមើលព័ត៌មានអំពីបន្ទុកលើអចលនវត្ថុ សូមចុចលើពាក្យ "ព័ត៌មានអំពីបន្ទុក" ពេលនោះលោកអ្នកនឹងឃើញអំពីតម្លៃសេវាចំនួន ២០ ០០០ រៀល ពីការទទួលព័ត៌មានសុរិយោដី ក្នុងមួយលើក។

បន្ទាប់មក សូមចុចលើប៊ូតុង "ចូលមើលព័ត៌មាន"




## ៣ ការបំពេញព័ត៌មានអ្នកស្នើសុំ និងការជ្រើសរើសធនាគារ

សូមបំពេញព័ត៌មានរបស់អ្នកស្នើសុំដូចខាងក្រោម÷

- បំពេញឈ្មោះ
- លេខទូរស័ព្ទ
- អ៊ីម៉ែល
- លេខកូដសុវត្ថិភាព។

បន្ទាប់មកសូមចុចប៊ូតុង "បញ្ជូន" ផ្ទាំងបញ្ជាក់ព័ត៌មានអ្នកស្នើសុំនឹងចេញមក។




បើលោកអ្នកពិនិត្យឃើញថា ព័ត៌មាន ដែលបានបំពេញ ពិតជាត្រឹមត្រូវហើយ សូមចុចប៊ូតុង "យល់ព្រមទូទាត់" ដើម្បីធ្វើការបង់ថ្លៃសេវា។




## ៤ ការបំពេញព័ត៌មានកាតសម្រាប់ការទូទាត់

សូមបំពេញព័ត៌មានកាត រួចចុចប៊ូតុង "Confirm and Pay"។
លោកអ្នកនឹងឃើញផ្ទាំងបញ្ជាក់ពីការបង់សេវា នឹងផ្ញើទៅកាន់អ៊ីម៉ែលរបស់លោកអ្នក។ បន្ទាប់មក សូមចុចប៊ូតុង "មើលព័ត៌មានបន្ទុក"។







## ៥ ការបង្ហាញព័ត៌មានអំពីបន្ទុកនៅលើអចលនវត្ថុ

ក្រោយចុចប៊ូតុង "មើលព័ត៌មានបន្ទុក" ព័ត៌មានអំពីបន្ទុកលើអចលនវត្ថុនឹងបង្ហាញដូចខាងក្រោម÷




| បន្ទុកលើអចលនទ្រព្យ | ឈ្មោះធនាគារ | ចំនួនទឹកប្រាក់(USD) | ថ្ងៃចាប់ផ្តើម | ថ្ងៃបញ្ចប់ | ថ្ងៃខែលើកលែ |
|---|---|---|---|---|---|
| - ការបញ្ចាំ | - ធនាគារវឌ្ឍនៈអាស៊ី | - | - 29-02-2012 | - 30-06-2018 | - 03-07-2018 |
| - ការបញ្ចាំ | - ធនាគារវឌ្ឍនៈអាស៊ី | - | - 19-06-2012 | - 30-06-2018 | - 03-07-2018 |
| - ការបញ្ចាំ | - ធនាគារវឌ្ឍនៈអាស៊ី | - | - 26-03-2014 | - 30-06-2018 | - 03-07-2018 |
| - ហ៊ីប៉ូតែក | - ធនាគារវឌ្ឍនៈអាស៊ី | - | - 19-03-2015 | - 30-06-2018 | - 03-07-2018 |


**ព័ត៌មានបន្ថែមសូមទំនាក់ទំនង**

(+855) 23 477 5777
www.mlmupc.gov.kh
www.facebook.com/mlmupc.pressteam





© រក្សាសិទ្ធិគ្រប់យ៉ាងដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

រៀបចំដោយ : នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
អាសយដ្ឋាន : លេខ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ